ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
លេខ: ១០៥/១៨ ក.អ.ជ.ប្រក

ថ្ងៃ ពុធ ១៤ កើត ខែ ចេត្រ ឆ្នាំ រកា ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មេសា គ.ស ២០១៨

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ប្រចាំក្រសួងអភិវឌ្ឍន៍ជនបទ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.**- បញ្ចប់តំណែងថ្នាក់ដឹកនាំ និងមន្ត្រីដែលស្ថិតក្នុងសមាសភាពគណៈកម្មាធិការលទ្ធកម្ម (គល) និងអង្គភាពលទ្ធកម្ម ប្រចាំក្រសួងអភិវឌ្ឍន៍ជនបទទាំងអស់ ដែលបានទទួលការតែងតាំងមុនថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១៦។

**ប្រការ ២.**- តែងតាំងសមាសភាពគណៈកម្មាធិការលទ្ធកម្ម (គល) ប្រចាំក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានរាយនាមដូចខាងក្រោម÷

| | | |
|---|---|---|
| ១. **ឯកឧត្តមបណ្ឌិត អ៊ុក រ៉ាប៊ុន** | រដ្ឋមន្ត្រី | ប្រធាន |
| ២. **ឯកឧត្តម សូស គង់** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. **ឯកឧត្តម ថ្វី មេង** | រដ្ឋលេខាធិការ | សមាជិក |
| ៤. **ឯកឧត្តម អ៊ុន ចន្ថា** | រដ្ឋលេខាធិការ | សមាជិក |
| ៥. **ឯកឧត្តម ហួត សារីម** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៦. **ឯកឧត្តម ថេង ច័ន្ទសង្វារ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៧. **ឯកឧត្តម សាន ចិសោល** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៨. **ឯកឧត្តម ទិម សំរិអ៊ែល** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៩. **ឯកឧត្តម យ៉ិន សុផល** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១០. **ឯកឧត្តម អ៊ុក ពញ្ញា** | នាយកខុទ្ទកាល័យ | សមាជិក |
| ១១. **ឯកឧត្តម ជួប សិរអាត** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ១២. **ឯកឧត្តម ចាន់ ដារ៉ុង** | អគ្គនាយកបច្ចេកទេស | សមាជិក |
| ១៣. **ឯកឧត្តម ប៊ុន ច័ន្ទវណ្ណៈ** | អគ្គាធិការ | សមាជិក |
| ១៤. **លោក គង់ គឿន** | ប្រធាននា. ផ្លូវលំជនបទ | សមាជិក |
| ១៥. **លោក ធាន សុម៉ារ៉ា** | ប្រធាននា. ផ្គត់ផ្គង់ និងហិរញ្ញវត្ថុ | សមាជិក |
| ១៦. **លោក ម៉ា សុវណ្ណា** | ប្រធាននា. ផែនការ និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ១៧. **លោក ឆួន គិរម្យ** | ប្រធាននា. រដ្ឋបាល និងបុគ្គលិក | សមាជិក |
| ១៨. **លោក ខួន តារា** | ប្រធានអង្គភាពលទ្ធកម្ម | លេខាធិការ |

**១៩. លោក លោកស្រី** តំណាងក្រសួងស្ថាប័នអង្គភាពពាក់ព័ន្ធ សមាជិក

**ប្រការ ៣.-** តែងតាំងសមាសភាពអង្គភាពលទ្ធកម្ម (អល) ប្រចាំក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានរាយនាមដូចខាងក្រោម÷

| | |
|---|---|
| **១. លោក ខួន តារា** | ប្រធាន |
| **២. លោក ឯក សុខិណា** | អនុប្រធាន |
| **៣. លោក គីម សេរីវុធ** | សមាជិក |
| **៤. លោក យូ ចិណ្ណាន** | សមាជិក |
| **៥. លោក ឌី ដារ៉ាវុធ** | សមាជិក |
| **៦. លោកស្រី កាយ សុឆាទី** | សមាជិក |
| **៧. លោកស្រី គង់ ចិសាខា** | សមាជិក |
| **៨. លោក ការ សុធី** | សមាជិក |
| **៩. លោក គង់ ចាន់ដេត** | សមាជិក |
| **១០. កញ្ញា ហែម សុហ៊ីយ៉ា** | សមាជិក |
| **១១. លោក អ៊ុច ចន្ទសុវណ្ណា** | សមាជិក |
| **១២. លោក យុន សុខលាង** | សមាជិក |

**ប្រការ ៤.-** គណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មសាធារណៈរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តតួនាទី និងភារកិច្ច ដូចមានកំណត់ក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១២ អនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១៥ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ប្រកាសលេខ ៣៨១ សហវ.ប្រក ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០១០ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ ៥.-** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦.**- នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរ អង្គភាពទាំងអស់ក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីជនដូចមានរាយនាមក្នុងប្រការ២ និងប្រការ៣ ត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  "*ដើម្បីជូនជ្រាប*"
- ដូចប្រការ ៦
  "*ដើម្បីអនុវត្ត*"
- ឯកសារកាលប្បវត្តិ

**បណ្ឌិត អ៊ុក រ៉ាប៊ុន**